**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៤០១ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៦

# ប្រកាស
## ស្តីពីការអនុវត្តន៍វិធីសាស្ត្រលទ្ធកម្មសាធារណៈ

ពស.ពល

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.កប ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញប្រកាសលេខ ៣១៩ សហវ.ប.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តនីតិវិធី និងបទប្បញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីតិវិធីសហមជ្ឈការៈលទ្ធកម្មសាធារណៈ

-យោងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់អោយអនុវត្តជាផ្លូវការនា ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤

## សំរេច

ប្រការ ១ : ប្រកាសនេះមានគោលបំណងកែសំរួល និង បំពេញបន្ថែមខ្លឹមសារមួយចំនួនក្នុងប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃ ទី ៣១ ខែ មករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។

ប្រការ ២ : ប្រការ២ នៃប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈត្រូវបានកែសំរួលដូចខាងក្រោម :

កំណត់វិធីសាស្ត្រលទ្ធកម្មតាមកំរិតទឹកប្រាក់ :

-ទឹកប្រាក់ក្រោម ២០លានរៀល អនុវត្តវិធីសាស្ត្រស្ទង់តំលៃ (Canvassing)

-ទឹកប្រាក់ចាប់ពី ២០លានរៀល ដល់ក្រោម ៥០លានរៀល អនុវត្តវិធីសាស្ត្រពិគ្រោះតំលៃ (Shopping)

-ទឹកប្រាក់ចាប់ពី ៥០លានរៀលឡើងទៅ អនុវត្តវិធីសាស្ត្រដេញថ្លៃជាសាធារណៈ ។

ប្រការ ៣ : ស្ថាប័នអនុវត្តលទ្ធកម្ម អាចចុះកិច្ចសន្យាផ្ទាល់ (Direct Contracting .DCo) ជាមួយអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការបាន ក្នុងករណីពិសេសណាមួយដូចខាងក្រោម :

១-ឧបករណ៍ដែលត្រូវការមានប្រភពតែមួយគត់

២-ករណីចាំបាច់សំរាប់ឆ្លើយតបនៅពេលមានគ្រោះមហន្តរាយធម្មជាតិកើតឡើង ហើយតម្រូវការចាំបាច់បន្ទាន់ ។

៣-សំរាប់គោលបំណងសិក្សា ស្រាវជ្រាវដកបទពិសោធន៍ ឬ អភិវឌ្ឍន៍

រាល់ការចុះកិច្ចសន្យាផ្ទាល់ទាំងអស់ ត្រូវមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៤ : រាល់បទប្បញ្ញត្តិទាំងឡាយណាពាក់ព័ន្ធក្នុងកិច្ចលទ្ធកម្មសាធារណៈ សំរាប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ ព្រមទាំងនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ក្រោមឳវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជ្រាបជារបាយការណ៍"
-ដូចប្រការ ៥
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ